KAISER PERMANENTE

# សេចក្ដីសង្ខេបអំពីគោលនយោបាយជំនួយហិរញ្ញវត្ថុវេជ្ជសាស្ត្រ

កម្មវិធីជំនួយហិរញ្ញវត្ថុផ្នែកវេជ្ជសាស្ត្ររបស់ Kaiser Permanente (Medical Financial Assistance, MFA) ផ្ដល់ជំនួយហិរញ្ញវត្ថុសម្រាប់អ្នកជំងឺដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ដែលត្រូវការជំនួយក្នុងការទូទាត់ប្រាក់សម្រាប់ការសង្គ្រោះបន្ទាន់ ឬការថែទាំចាំបាច់ផ្នែកវេជ្ជសាស្ត្រដែលពួកគេទទួលបានក្នុងមន្ទីរពេទ្យ Kaiser Permanente ឬតាមរយៈអ្នកផ្ដល់សេវារបស់ Kaiser Permanent។ អ្នកជំងឺអាចដាក់ពាក្យសម្រាប់កម្មវិធី MFA តាមវិធីជាច្រើន ដូចជាតាមអនឡាញ ដោយផ្ទាល់ តាមទូរស័ព្ទ ឬតាមការបំពេញ ឬការដាក់ជូនពាក្យសុំជាក្រដាស។ អ្នកជំងឺត្រូវតែបំពេញតាមលក្ខខណ្ឌតម្រូវនៃលក្ខណសម្បត្តិគ្រប់គ្រាន់ខាងក្រោមដើម្បីមានលក្ខណសម្បត្តិគ្រប់គ្រាន់។

### តើនរណាអាចមានសិទ្ធិទទួលបានលក្ខណៈសម្បត្តិសម្រាប់ជំនួយហិរញ្ញវត្ថុ ហើយតើលក្ខខណ្ឌតម្រូវមានអ្វីខ្លះ?

កម្មវិធីនេះជួយអ្នកជំងឺដែលមានប្រាក់ចំណូលទាប ដែលមិនត្រូវបានធានា ឬដែលទទួលបានសេវាមិនគ្រប់គ្រាន់ដែលត្រូវការជំនួយក្នុងការទូទាត់ប្រាក់សម្រាប់ការថែទាំវេជ្ជសាស្ត្រទាំងអស់ ឬមួយផ្នែក។ ជាទូទៅ អ្នកជំងឺអាចមានលក្ខណសម្បត្តិទទួលជំនួយហិរញ្ញវត្ថុ នៅពេលប្រាក់ចំណូលគ្រួសារដុលសរុបរបស់ពួកគេនៅត្រឹម ឬក្រោម 400% នៃគោលការណ៍ណែនាំរបស់សហព័ន្ធស្ដីពីភាពក្រីក្រ (Federal Poverty Guidelines, FPG) ឬមានការចំណាយផ្នែកវេជ្ជសាស្ត្រខ្ពស់ខុសពីធម្មតា។ អ្នកជំងឺគួរតែនិយាយជាមួយទីប្រឹក្សាហិរញ្ញវត្ថុ ដើម្បីកំណត់ការទទួលសិទ្ធិ និងសម្រាប់ការដាក់ពាក្យសុំជំនួយ។

*អ្នកជំងឺដែលអាចមានលក្ខណសម្បត្តិទទួលជំនួយហិរញ្ញវត្ថុផ្នែកវេជ្ជសាស្ត្រ មិនមានការគិតថ្លៃច្រើនជាងចំនួនទឹកប្រាក់ដែលបានចេញវិក័យប័ត្រ (Amounts Generally Billed, AGB) សម្រាប់ការសង្គ្រោះបន្ទាន់ ឬការថែទាំចាំបាច់ផ្នែកវេជ្ជសាស្ត្រផ្សេងៗទៀត។ សូមមើល kp.org/mfa/nw សម្រាប់ព័ត៌មាន AGB។*

### តើ Kaiser Permanente ពិនិត្យអ្នកជំងឺសម្រាប់សិទ្ធិទទួលកម្មវិធីជាសាធារណៈ ឬឯកជនឬទេ?

Kaiser Permanente ផ្ដល់ឲ្យអ្នកជំងឺជាមួយនឹងជំនួយដើម្បីកំណត់កម្មវិធីធានារ៉ាប់រងសុខភាពជាសាធារណៈ ឬឯកជនដែលមានសក្ដានុពលដែលអាចជួយបំពេញតម្រូវការនៃការទទួលបានការថែទាំសុខភាព។ អ្នកជំងឺដែលត្រូវបានសន្មត់លក្ខណសម្បត្តិទទួលបានកម្មវិធីធានារ៉ាប់រងសុខភាពជាសាធារណៈ ឬឯកជនតម្រូវឲ្យដាក់ពាក្យសុំសម្រាប់កម្មវិធីទាំងនេះ។

### តើកម្មវិធីធានារ៉ាប់រងអ្វីខ្លះ?

កម្មវិធីជំនួយហិរញ្ញវត្ថុវេជ្ជសាស្ត្រធានាទាំងស្រុងឬដោយផ្នែកលើការថែទាំចាំបាច់ផ្នែកវេជ្ជសាស្ត្រដែលបានផ្ដល់នៅការិយាល័យវេជ្ជសាស្ត្ររបស់ Kaiser Permanente មន្ទីរពេទ្យ ឱសថស្ថាន ឬបានផ្ដល់តាមរយៈអ្នកផ្ដល់សេវាថែទាំរបស់ Kaiser Permanente។ ប្រភេទនៃសេវាដែលមិនរាប់បញ្ចូល មានដូចជាសេវាដែលមិនចាត់ទុកជាការសង្គ្រោះបន្ទាន់ ឬភាពចាំបាច់ផ្នែកវេជ្ជសាស្ត្រតាមរយៈអ្នកផ្ដល់សេវាថែទាំរបស់ Kaiser Permanente ការព្យាបាលភាពមិនមានលទ្ធផលបង្កបង្កើត ឬសេវាវះកាត់ និងប្រាក់បុព្វលាភសម្រាប់ការថែទាំសុខភាព។ សូមមើលបញ្ជីព័ត៌មានពេញលេញកាន់តែច្រើនក្នុងគោលនយោបាយ MFA។

### តើមានជំនួយផ្នែកភាសាដែរឬទេ?

មានអ្នកបកប្រែសម្រាប់អ្នកដោយឥតគិតថ្លៃ។ ពាក្យសុំជំនួយហិរញ្ញវត្ថុផ្នែកវេជ្ជសាស្ត្រ គោលនយោបាយ និងសេចក្ដីសង្ខេបស្ដីពីគោលនយោបាយអាចមានជាភាសារបស់អ្នក។ សម្រាប់ព័ត៌មានបន្ថែម សូមទូរស័ព្ទទៅលេខ 800-324-8010 ឬចូលមើលវិបសាយរបស់យើងតាម kp.org/mfa/nw។

### តើ Kaiser Permanente មានគោលនយោបាយស្ដីពីជំនួយហិរញ្ញវត្ថុដែរឬទេ?

អ្នកអាចស្នើសុំច្បាប់ចម្លងនៃគោលនយោបាយជំនួយហិរញ្ញវត្ថុផ្នែកវេជ្ជសាស្ត្ររបស់ Kaiser Permanente ដោយឥតគិតថ្លៃ ដោយទូរស័ព្ទទៅកាន់លេខ 800-813-2000 ផ្ញើសំបុត្រទៅ 500 NE Multnomah Street, Suite 100, Portland, OR 97232 ឬដោយចូលទៅមើលគេហទំព័ររបស់យើងតាមរយៈ kp.org/mfa/nw។

### តើត្រូវការជំនួយឬទេ?

សម្រាប់ជំនួយ ឬសំណួរអំពីដំណើរការដាក់ពាក្យសុំជំនួយហិរញ្ញវត្ថុផ្នែកវេជ្ជសាស្ត្រ សូមទូរស័ព្ទទៅ 800-813-2000 ឬនិយាយជាមួយទីប្រឹក្សាហិរញ្ញវត្ថុ នៅក្បែរផ្នែកសេវាការងារប្រើប្រាស់របស់អ្នកជំងឺ នៅឯមន្ទីរពេទ្យ Kaiser Permanente ណាមួយ។

### តើខ្ញុំដាក់ពាក្យសុំដោយរបៀបណា?

អ្នកអាចដាក់ពាក្យសុំសម្រាប់ជំនួយហិរញ្ញវត្ថុផ្នែកវេជ្ជសាស្ត្រតាមវិធីជាច្រើន -- តាមរយៈការស្នើសុំព័ត៌មានស្ដីពីកម្មវិធីដោយផ្ទាល់ ឬតាមទូរស័ព្ទ ឬការស្នើសុំពាក្យសុំជាក្រដាសពីប្រភពនានាដូចខាងក្រោម៖

- តាមអនឡាញនៅវិបសាយ kp.org/mfa/nw
- ទីប្រឹក្សាហិរញ្ញវត្ថុនៅក្បែរផ្នែកសេវាការងារប្រើប្រាស់របស់អ្នកជំងឺ ឬតុចុះឈ្មោះនៅឯមន្ទីរពេទ្យ Kaiser Permanente ណាមួយ
- សូមទូរស័ព្ទទៅលេខ 800-813-2000
- តាមសំបុត្រប្រៃសណីយ៍ (ដោយឥតគិតថ្លៃ) នៅឯ 500 NE Multnomah Street, Suite 100, Portland, OR 97232
- ទាញយកពាក្យសុំតាមរយៈវិបសាយសហគមន៍របស់ Kaiser Permanente នៅ kp.org/mfa/nw។

សូមប្រគល់ពាក្យសុំដែលបំពេញរួច (រួមមានឯកសារ និងព័ត៌មានទាំងអស់ដែលតម្រូវដែលបានកំណត់ក្នុងសេចក្ដីណែនាំស្ដីពីការដាក់ពាក្យសុំ) ទៅតុចុះឈ្មោះរបស់មន្ទីរពេទ្យ Kaiser Permanente ដែលនៅជិតបំផុត ឬផ្ញើពាក្យសុំទៅ៖ MFA Program, 500 NE Multnomah Street, Suite 100, Portland, OR 97232។

Kaiser Permanente នឹងពិនិត្យពាក្យសុំដែលដាក់ជូន នៅពេលឯកសារទាំងនេះបំពេញរួចរាល់ ហើយនឹងកំណត់ថាតើអ្នកអាចមានលក្ខណសម្បត្តិទទួលជំនួយដោយស្របតាមគោលនយោបាយស្ដីពីជំនួយហិរញ្ញវត្ថុផ្នែកវេជ្ជសាស្ត្ររបស់ Kaiser Permanente ឬទេ។ ពាក្យសុំដែលមិនបានបំពេញរួច អាចបណ្ដាលឲ្យមានការពន្យារពេលក្នុងដំណើរការ ឬការបដិសេធពាក្យសុំ MFA របស់លោកអ្នក ប៉ុន្តែ Kaiser Permanente នឹងជូនដំណឹងដល់ពាក្យសុំ និងផ្ដល់ឱកាសក្នុងការផ្ញើឯកសារ ឬព័ត៌មានដែលបាត់តាមថ្ងៃផុតកំណត់ដែលបានតម្រូវ។

©2021 Kaiser Foundation Hospital;
Kaiser Foundation Health Plan of the Northwest